# សេចក្ដីជូនដំណឹងអំពីការចាក់វ៉ាក់សាំងបន្ថែម ដើម្បីការពារកូវីដ-១៩ សម្រាប់ជនបរទេសក្នុងរដ្ឋខេត្ត

សូមចូលរួមយ៉ាងសកម្មក្នុងការចាក់វ៉ាក់សាំងបន្ថែម ដើម្បីការការពារជំងឺកូវីដ-១៩នៅរដូវរងារនេះ
សម្រាប់បង្ការជំងឺធ្ងន់ធ្ងរនិងការស្លាប់ដល់អ្នកដែលងាយរងគ្រោះផ្នែកសុខភាព!

## អ្នកដែលមានអាទិភាពក្នុងការចាក់វ៉ាក់សាំង

អ្នកដែលមានអាយុលើសពី18ឆ្នាំ ហើយបានចាក់វ៉ាក់សាំងមូលដ្ឋានរួចរាល់

**① អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ**

**② មានអាយុលើសពី60ឆ្នាំ**

**③ អ្នកជំងឺ.អ្នកចូលស្នាក់ នៅមណ្ឌល.មន្ទីរពេទ្យ ចាស់ជរា នឹងនៅមណ្ឌលដែលងាយរងគ្រោះនិងការឆ្លងជំងឺ**

## ប្រភេទវ៉ាក់សាំង

**វ៉ាក់សាំងដែលមានអង់ទីករ2ផ្សេងគ្នា ដោយផ្អែកលើ BA.1 (វ៉ាក់សាំង mRNA)**

※ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើបុគ្គលដែលមានការហាមឃាត់ ឬពន្យារពេលការចាក់វ៉ាក់សាំង mRNA ឬអ្នកដែលមិនចង់ទទួលការចាក់វ៉ាក់សាំង mRNAនោះ ក៏មានវ៉ាក់សាំងដែលផ្សំពីប្រូតេអ៊ីនឡើងវិញ(វ៉ាក់សាំង ណូវ៉ាវ៉ាក់, វ៉ាក់សាំង Skycobi One )ចាក់ជូនផងដែរ។

## ចន្លោះពេលនៃការចាក់វ៉ាក់សាំង

**បន្ទាប់ពីរយៈពេល 4ខែ(120 ថ្ងៃ)**
ចាប់ពីថ្ងៃ**ចាក់វ៉ាក់សាំងចុងក្រោយ ឬ**
ក្រោយថ្ងៃ**កាលបរិច្ឆេទធ្វើរោគវិនិច្ឆ័យ**

## វិធីសាស្ត្រនៃការចាក់វ៉ាក់សាំង

☐ ជនបរទេសដែលមានកាតសម្គាល់ខ្លួន : ការកក់ទុកជាមុនតាមអនឡាញ, ការកក់តាមទូរស័ព្ទ និងការទទួលវ៉ាក់សាំង នៅថ្ងៃនោះតែម្ដង

**※ ការកក់ទុកមុន ចាប់ពី(អង្គារ៍)ថ្ងៃទី២៧ ខែកញ្ញា ~ ថ្ងៃចាប់ផ្ដើមចាក់វ៉ាក់សាំង(ចាក់ថ្ងៃនោះតែម្ដង) (អង្គារ៍)ថ្ងៃទី១១ ខែតុលា ~**

☐ **ជនបរទេសរស់នៅខុសច្បាប់** : ធ្វើការកក់ទុកតាមទូរស័ព្ទ ឬទៅស្ថាប័នចាក់វ៉ាក់សាំងផ្ទាល់ បន្ទាប់ពីចេញលេខគ្រប់គ្រងបណ្ដោះអាសន្ន នៅមណ្ឌលសុខភាពសាធារណៈ។

☐ **ជនបរទេសដែលបានបញ្ចប់ការចាក់វ៉ាក់សាំងជាមូលដ្ឋាននៅបរទេស** : ធ្វើការកក់ទុក បន្ទាប់ពីចុះឈ្មោះប្រវត្តិចាក់ថ្នាំនៅក្រៅប្រទេស នៅមណ្ឌលសុខភាពសាធារណៈរួចរាល់ ។

## ※ ព័ត៌មានផ្សេងៗ

○ **វ៉ាក់សាំងដែលនៅសេសសល់ត្រូវបានអនុញ្ញាតឱ្យចាក់ជូនដល់មនុស្សពេញវ័យដែលមានអាយុចាប់ពី18ឆ្នាំឡើងទៅ។**

○ **គេហទំព័រ កក់តាមអនឡាញ** : https://ncvr.kdca.go.kr

○ **ការកក់ទុកតាមទូរស័ព្ទ** : មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ ទូរស័ព្ទលេខ(☎1339) ឬទូរស័ព្ទកក់ទុកមុន ទៅមណ្ឌលតាមអង្គភាពស្វយ័តក្នុងតំបន់

○ **ការចាក់វ៉ាក់សាំងក្នុងថ្ងៃនោះតែម្ដង** : ការកក់ចាក់វ៉ាក់សាំងដែលនៅសេសសល់ អ្នកអាចឆែកមើលនៅលើបណ្ដាញSNS (KakaoTalk, Naver) រឺការហៅទូរស័ព្ទទៅកាន់ស្ថាប័នវេជ្ជសាស្ត្រដោយផ្ទាល់។